Buddhist Council of NSW
Working for the Buddhist Community

# ការឆ្លើយតបរបស់ព្រះពុទ្ធចំពោះសេចក្តីថ្លែងការណ៍ Uluru (Uluru Statement) ដោយស្មោះចេញពីបេះដូង

*រៀបចំបង្កើតឡើងដោយអ្នកតំណាងនៃសហគមន៍ពុទ្ធសនិកជនចម្រុះនៅឯសិក្ខាសាលាដែលបានកោះប្រជុំដោយក្រុមប្រឹក្សាពុទ្ធសនិកជននៃរដ្ឋញូវសៅវែល (Buddhist Council of NSW ) ក្នុងក្រុងស៊ីដនី នៅថ្ងៃទី 2 ខែកញ្ញា ឆ្នាំ 2023។*

**ការអញ្ជើញ**

នៅក្នុងសេចក្តីថ្លែងការណ៍Uluruដោយស្មោះចេញពីបេះដូងរបស់ប្រជាជនដំបូង(First Peoples) នៃប្រទេសអូស្ត្រាលី អំពាវនាវឱ្យ Voice (សំឡេង) តម្កល់ទុកក្នុងរដ្ឋធម្មនុញ្ញ ការពិតប្រាប់អំពី ប្រវត្តិសាស្ត្ររបស់ប្រទេសអូស្ត្រាលី និងដំណើការនៃកិច្ចព្រមព្រៀងដែលធ្វើឡើងរវាងរដ្ឋាភិបាលនានា និងប្រជាជននៃប្រជាជាតិដំបូង (First Nations)។ ពួកគេអញ្ជើញយើងទាំងអស់គ្នាឱ្យធ្វើដំណើរ ដោយធ្វើរដើងជាមួយពួលគេក្នុងចលនាមួយរបស់ប្រជាជនអូស្ត្រាលីសម្រាប់អនាគតមួយកាន់តែប្រសើរឡើង។

**ប្រវត្តិសាស្ត្ររបស់យើង**

ប្រជាជនដំបូង (First Peoples) របស់ប្រទេសអូស្ត្រាលីគឺជាប្រជាជនចាស់ជាងគេបំផុតដែលកំពុង បន្តវប្បធម៌នៅក្នុងពិភពលោក បានកំពុងរស់នៅទីនេះអស់រយៈពេលច្រើនជាងហុកសិបពាន់ឆ្នាំ មកហើយ។ ចាប់តាំងពីឆ្នាំ1788 ផលប៉ះពាល់នៃការធ្វើអាណានិគម - ការប្រល័យពូជសាសន៍ ការដកហូតកម្មសិទ្ធិនៃដីរបស់ពួកគេ ការដកចេញដោយបង្ខំនូវកូនៗរបស់ពួកគេ និង ការហាមឃាត់ក្នុងការប្រតិបត្តិវប្បធម៌ និងភាសារបស់ពួកគេ - បន្តប៉ះពាល់ដល់ពួកគេ គ្រួសារ និងសហគមន៍របស់ពួកគេ។ ដោយគ្មានសន្ធិសញ្ញារវាងពួកឈ្លានពាន និងប្រជាជននៃ ប្រជាជាតិដំបូង (First Nations Peoples) ទឹកដីមិនដែលត្រូវបានប្រគល់ឱ្យទេ។ ខណៈពេលដែលពួកគេមានភាពធន់ រក្សាវប្បធម៌របស់ពួកគេ  យកមកអនុវត្តនូវភាសា របស់ពួកគេឡើងវិញ និងបង្កើតទីកន្លែងក្នុងប្រទេសអូស្ត្រាលីនាពេលបច្ចុប្បន្ន ប្រជាជននៃប្រជាជាតិដំបូង (First Nations Peoples)  ជាច្រើននៅតែត្រូវបាន គេចាត់ទុកថាមិនសំខាន់ ហើយអាស្រ័យដោយការរើសអើង និងការប្រកាន់ពូជសាសន៍ តាមស្ថាប័ន ដែលនាំមកនូវលទ្ធផលក្នុងផ្នែកសុខភាព ការអប់រំ និងទ្រព្យសម្បត្តិ កាន់តែមិនល្អ ព្រមទាំងមានអត្រានៃការជាប់ពន្ធធនាគារខ្ពស់មិនមានសមាមាត្រ។

**ភាពចម្រុះខាងវប្បធ៌របស់យើង**

សហគមន៍ពុទ្ធសនិករបស់ប្រទេសអូស្ត្រាលីចេញមកពីទឹកដីជាច្រើន ហើយនិយាយភាសាជាច្រើន។ យើងជាច្រើននាក់បានមកដល់ប្រទេសអូស្ត្រាលីក្នុងនាមជាជនភៀសខ្លួន ឬអ្នកចំណាកស្រុក ផ្នែកសេដ្ឋកិច្ចជាកចេញពីស្រុកកំណត់ដើមរបស់យើង ដើម្បីរៀបចំរបស់យើងផ្ទាល់ និងរក្សា វប្បធម៌របស់យើងឱ្យដំណើរការដូចសព្វថ្ងៃដែលយើងហៅថាផ្ទះ។ យើងប្រហែលជាធ្លាប់មានឱកាស តិចតួចក្នុងការចូលរួមជាមួយប្រជាជនអូស្ត្រាលីជាជនជាតិដើម Indigenous (Indigenous Australians) ប៉ុន្តែដឹងផងដែរវាអាចដូចអ្វីដែរក្នុងការខ្វះខាតសំឡេង និងជាមនុស្សចម្លែកម្នាក់នៅលើ ទឹកដីផ្ទាល់ខ្លួនរបស់ខ្លួន។

**គុណតម្លៃពុទ្ធសនិកជនរបស់យើង**

យើងសូមសំដែងការដឹងគុណចំពោះអំណោយទាំងឡាយដែលប្រជាជនដំបូង (First Peoples) របស់ ប្រទេសអូស្ត្រាលីបានចែករំលែកជាមួយយើង៖ វប្បធម៌របស់ពួកគេ ទំនាក់ទំនងទៅនឹងប្រទេស និងការប្តេជ្ញាចិត្តចំពោះគ្រួសារ និងសហគមន៍។ យើងដាក់ខ្លួនដោយការអភ័យទោសរបស់ ពួកគេចំពោះទង្វើខុសឆ្គងពីអតីតកាល និងបច្ចុប្បន្នកាល។ យើងទទួលស្គាល់ភាពស្រដៀងគ្នា ក្នុងគុណតម្លៃនៃភាពចិត្តល្អ-សេចក្តីស្រឡាញ់របស់យើង ចិត្តមេត្តាធម៌ និងក្តីរីករាយប្រកប ដោយសមានចិត្ត ការទទួលស្គាល់ទំនាក់ទំនងស៊ីជម្រៅរបស់យើងរវាងអ្វីៗទាំងអស់ និង ការអនុវត្តមនសិកា ʙយកចិត្តទុកដាក់ និងការស្តាប់ស៊ីជម្រៅរបស់យើង។ យើងក៏ទទួលស្គាល់ផងដែរនូវសេចក្តីសម្រាប់ការប្រាប់ការពិត

ដើម្បីឱ្យយើងអាចរួមជាមួយគ្នាក្នុងការដោះស្រាយភាព អយុត្តិធម៌ទាំងឡាយ និងព្យាបាលការឈឺចាប់ដល់យើងទាំងអស់គ្នាដែលហៅប្រទេសអូស្ត្រាលីថាជាផ្ទះ។

**ការឆ្លើយតបពុទ្ធសនិកជនរបស់យើង**

យើងទទួលយកដោយកតញ្ញូតាធម៌ចំពោះការអញ្ជើញដើម្បីធ្វើដំណើរដោយធ្វើរជើង ដើម្បី បង្កើតប្រទេសអូស្ត្រាលីមួយដែលប្រជាជននៃប្រជាជាតិដំបូង (First Nations Peoples)  និងប្រជាជនអូស្ត្រាលីមិនមែនជាជនជាតិដើម មករួមគ្នានៅក្នុងសង្គមមួយប្រកបដោយយុត្តិធម៌ និងមានភាពស្អិតរមួតនឹងគ្នា។ យើងទន្ទឹងរង់ចាំការជាសះស្បើយនោះ ដែលនឹងចេញមកពី ការទទួលស្គាល់ការពិតជាមួយនឹងអតីតកាល បច្ចុប្បន្នកាលរបស់ប្រទេសអូស្ត្រាលី។ យើងគាំទ្រដល់សំឡេង (Voice)សម្រាប់ប្រជាជននៃប្រជាជាតិដំបូង (First Nations Peoples) ដូច្នេះយើងទាំងអស់គ្នាអាចទទួលបានអត្ថប្រយោជន៍ពីគតិបណ្ឌិត និងបទពិសោធន៍រស់នៅ របស់ពួកគេ ព្រមទាំងទំនាក់ទំនងរបស់ពួកគេ និង ការយល់ដឹងអំពីពិភពធម្មជាតិ នៅពេល យើងប្រឈមនឹងវិបត្តិអាកាសធាតុ និងវិបត្តិផ្នែកអេកូលីស៊ីនៃពេលវេលា របស់យើង។

**សូមមនុស្សជាតិទាំងអស់មានសុភមង្គល និងមានបុព្វហេតុដើម្បីសុភមង្គល**